## កំណត់ហេតុប្រជុំកិច្ចព្រមព្រាងរវាង

## តំណាងក្រុមហ៊ុនហាណា ជាមួយប្រតិនិធិបុគ្គលិកទាំង ០៨ រូប រួមទាំងកម្មករ កម្មការនី ក្នុងការឈប់សម្រាក

## បណ្តោះអាសន្ន

ឆ្នាំពីរពាន់ម្ភៃបួន ខែ ធ្នូ ថ្ងៃទី ០៣ វេលាម៉ោង មួយរសៀល នៅការិយាល័យរបស់ក្រុមហ៊ុនហាណាម៉ាយក្រូអេឡិកត្រូនិកបានរៀបចំកិច្ចប្រជុំមួយដែលប្រព្រឹត្តទៅ ក្រោមអធិបតីភាពរបស់ លោក PRATHUANG PANKHAM ប្រធានគ្រប់គ្រងផ្នែកផលិត និង ធនធានមនុស្ស និង លោក ហ៊ិន បូរី និង កញ្ញា គឹម មន្ថា ប្រធានផ្នែកធនធានមនុស្ស របស់ក្រុមហ៊ុនហាណាម៉ាយក្រូអេឡិកត្រូនិក។

<u>សមាសភាពចូលរួមប្រជុំមាន:</u> (ដូចមានបញ្ជីវត្តមានភ្ជាប់មកជាមួយ)

<u>ការប្រព្រឹត្តនៅក្នុងអង្គប្រជុំ:</u>

**របៀបវារៈ១៖ ការបើកអង្គប្រជុំ និង សំណេះសំណាល**

លោកប្រធានអង្គប្រជុំ បានជួបសំណេះសំណាល ក៏ដូចជាសួរសុខទុក្ខទៅកាន់ប្រតិភូបុគ្គលិកទាំងអស់ និង ប្រធានផ្នែក ក៏ដូចជាបុគ្គលិកដែលមានវត្តមាន ប្រាប់ពីគោលបំណងនៃអង្គប្រជុំ បន្ទាប់ពីជួបសំណេះសំណាលរួចលោក បានប្រកាសអង្គប្រជុំ តែម្តង។

**របៀបវារៈ២៖ ការពិភាក្សាអំពីកិច្ចព្រមព្រាងនៃការឈប់សម្រាកបណ្តោះអាសន្ន**

<u>លក្ខខណ្ឌនៃការធ្វើឈប់សម្រាកបណ្តោះអាសន្ន</u>

**ប្រការ១៖** ការព្យួរការងារបណ្តោះអាសន្នសម្រាប់កម្មករនិយោជិតផលិតកម្ម៖

- ការព្យួរការងារបណ្តោះអាសន្ន ដែលនឹងត្រូវធ្វើឡើង ៖

បុគ្គលិកក្រុមហ៊ុនហាណាផ្នែកផលិត ចំនួន ១២៧នាក់ ក្នុងចំណោមបុគ្គលិកសរុប ១៧៨នាក់ ប្រុសចំនួន ៣៣នាក់ និង ស្រីចំនួន ៩៤នាក់ ព្យួរការងារចាប់ពីថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០២៤ រហូតដល់ថ្ងៃទី ២៧ខែធ្នូ ឆ្នាំ ២០២៤។ ដោយសារស្ថានភាពបច្ចុប្បន្នការផលិតមានការថយចុះ ធ្លាក់ការបញ្ជាទិញពីអតិថិជនដោយសារវិបត្តិសកល ។

**ប្រការ២៖** ក្នុងកំឡុងពេលព្យួរបណ្តោះអាសន្នក្រុមហ៊ុនផ្តល់ជូនប្រាក់ឈ្នួលអប្បរមា និង អត្ថប្រយោជន៍ជូនកម្មករនិយោជិតដូចខាងក្រោម៖

- ប្រាក់ឧបត្ថម្ភ ៥០ % នៃប្រាក់ឈ្នួលគោល
- ប្រាក់ឧស្សាហ៍ ១០០ %
- ប្រាក់ឧបត្ថមស្នាក់នៅ ១០០ %

តារាងបើកប្រាក់ឈ្នួលរបស់ក្រុមហ៊ុនគឺលើកទី១ នៅថ្ងៃទី ១៤ និង លើកទី២នៅថ្ងៃទី ២៨ នៃខែនីមួយៗ ការបើកប្រាក់ឧបត្ថម្ភនេះគឺបើកជូននៅលើកទី២ ថ្ងៃទី២៧ នៃខែធ្នូ ឆ្នាំ ២០២៤។

**ប្រការ៣៖** យោងតាមច្បាប់ការងារមាត្រាទី ៧១ និង មាត្រាទី៧២ ដើម្បីរក្សាបានស្ថេរភាពក្នុងក្រុមហ៊ុនបាន និង ជួយសម្រួលដល់ជីវភាពប្រចាំថ្ងៃរបស់បុគ្គលិកបានសមរម្យ ក្រុមហ៊ុនផ្តល់ជូនប្រាក់ឧបត្ថម្ភ និង អត្ថប្រយោជន៍ ។

**របៀបវារៈ៣ សំណួរ របស់បងប្អូនប្រតិភូបុគ្គលិក និង ការប្រកាសបិទអង្គប្រជុំ**

ប្រតិភូបុគ្គលិក លោក ផន សុភក្រ្ត័ កញ្ញា ម៉ារីណា និង លោក ឈុំ ស៊ីណា សូមអោយភាគី តំណាងក្រុមហ៊ុន ជួយបញ្ជាក់បន្ថែមពីថ្ងៃអត្ថប្រយោជន៍កម្មករនិយោជិត និង សិទ្ធិដែលពួកគាត់អាច ទទួលបានក្នុងកំឡុងពេលព្យួរការងារ បណ្តោះអាសន្ន ។

ដោយមានសំណួរបញ្ជាក់បន្ថែម ភាគីតំណាងនិយោជក កញ្ញាគឹម មន្ថា ដែលជាប្រធានផ្នែកធនធានមនុស្សបានធ្វើការបកស្រាយនិងពន្យល់លំអិតពីការផ្តល់ជូនប្រាក់ឧបត្ថម្ភ៥០%នៃប្រាក់ឈ្នួលគោល និង ការផ្តល់ជូន អត្ថប្រយោជន៍ផ្សេងៗ និង·បានធ្វើការបញ្ជាក់ពីលក្ខខណ្ឌដែលបងប្អូនបុគ្គលិកត្រូវទទួលបាន ។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង បី រសៀល ក្រោមបរិយាកាសដ៏ស្និទ្ធស្នាល និងទទួលបានលទ្ធផលល្អប្រសើរ ។

| អ្នកធ្វើរបាយការណ៍ | អ្នកទទួលជ្រាប | អ្នកទទួលជ្រាប |
| --- | --- | --- |
| លោក ឡុង វុត្ថា | លោក ដួង គឹមម៉េង | លោក Prathuang Pankham |
| បុគ្គលិកផ្នែកធនធានមនុស្ស | ប្រតិភូបុគ្គលិកពេញសិទ្ធិ | ជ.នាយកក្រុមហ៊ុន |

ក្រុមហ៊ុន ហាណា
ម៉ាយក្រូអេឡិចត្រូនិក (ខេមបូឌា)
HANA MICROELECTRONICS (CAMBODIA) CO., LTD.
KINGDOM OF CAMBODIA

ភ្ជាប់មកជាមួយនូវៈ
បញ្ជីអវត្តមាន
ចំលងជូនៈ

- -គ្រប់ប្រធានផ្នែក
- -សមាជិក អង្គប្រជុំ ដើម្បីអភិវឌ្ឍន៍
- -ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

---

**ក្រុមហ៊ុនហាណាម៉ាយក្រូអេឡិកត្រូនិក (ខេមបូឌា)**

កោះកុងថ្ងៃទី ...០៣....... ខែ ...ធ្នូ......... ឆ្នាំ ២០២៤

## សេចក្តីបញ្ជាក់

យើងខ្ញុំជាប្រតិភូបុគ្គលិកនៃ ក្រុមហ៊ុនហាណា បានពិនិត្យ និងយល់ឃើញថា ក្នុងក្រុមហ៊ុនហាណា ពិតជាមានតម្រូវការចាំបាច់អោយកម្មករ កម្មការនី និងនិយោជិតមួយចំនួន ព្យួរការងារបណ្តោះអាសន្ន ដោយយោងតាមស្ថានភាពបច្ចុប្បន្នការផលិតមានការថយចុះ ដែលធ្វើអោយមានការប៉ះពាល់ដល់ដំណើរផលិតចាប់ពីថ្ងៃទី១៦ ដល់ថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ ២០២៤ ។

ដើម្បីគ្រប់គ្រងស្ថានភាពសេដ្ឋកិច្ចក្រុមហ៊ុនអោយមានស្ថេរភាព និង ដើម្បីរក្សាស្ថានភាពជីវភាពរបស់កម្មករនិយោជិតអោយបានសមរម្យ ដោយក្រុមហ៊ុនបានផ្តល់ជូនប្រាក់ឧបត្ថម្ភដូចបានរៀបរាប់ខាងក្រោម ៖

- ប្រាក់ឧបត្ថម្ភ ៥០% នៃប្រាក់ឈ្នួលគោល
- ប្រាក់ឧស្សាហ៍ ១០០%
- ប្រាក់ឧបត្ថម្ភស្នាក់នៅ ១០០%

យើងខ្ញុំទាំងអស់គ្នាបានឯកភាពតាមសំណើររបស់ លោកនាយកក្រុមហ៊ុន ហាណាម៉ាយក្រូអេឡិកត្រូនិក ហើយសូមបញ្ជាក់ថាកម្មករ កម្មការនី និងនិយោជិត យល់ព្រមតាមការស្នើសុំរបស់ក្រុមហ៊ុនដោយយោងតាមសេចក្តីបញ្ជាក់ពីស្ថានភាពរបស់ក្រុមហ៊ុនដូចបានរៀបរាប់ខាងលើ ។

ក្រែងពុំពិតប្រាកដ យើងខ្ញុំសូមផ្តិតមេដៃទុកជាភស្តុតាង។

**ប្រតិភូតំណាងបុគ្គលិក**

ក្រុមហ៊ុន ហាណា ម៉ាយក្រូអេឡិកត្រូនិក (ខេមបូឌា)
HANA MICROELECTRONICS (CAMBODIA) CO., LTD.
KINGDOM OF CAMBODIA